ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

លេខ: ០៤៤/១៧ គ.ជ.ប.ជ

# របាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែកុម្ភៈ និងទិសដៅខែមីនា ឆ្នាំ២០១៧

( គិតចាប់ពីថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៥ ខែកុម្ភៈឆ្នាំ២០១៧ )

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (**គ.ជ.ប.ជ**) បានពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញការសម្របសម្រួល ជាមួយក្រុមការងារអន្តក្រសួង ស្ថាប័ន ព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានា សុំឲ្យមានការស្រាវជ្រាវស៊ើបអង្កេតបទល្មើស និងសិក្សាពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ។

អគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលរបាយការណ៍បូកសរុបពី៖ ក្រុមការងារកិច្ចការយុត្តិធម៌(ក្រសួងយុត្តិធម៌) ,ក្រុមការងារការពារជនរងគ្រោះ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការនគរបាលជាតិ) និងលេខាធិការដ្ឋានរាជធានី/ខេត្តចំនួន២៤ (រាជធានីភ្នំពេញ ,កោះកុង ព្រះសីហនុ ,កំពត ,កែប ,តាកែវ ,កណ្តាល ,ព្រៃវែង ,ឧត្តរមានជ័យ ,ប៉ៃលិន ,បន្ទាយមានជ័យ ,បាត់ដំបង ,ពោធិ៍សាត់ កំពង់ឆ្នាំង ,ព្រះវិហារ ,សៀមរាប ,កំពង់ធំ ,ក្រចេះ ,ស្ទឹងត្រែង ,រតនគិរី ,មណ្ឌលគិរី ,កំពង់ចាម ,ព្រៃវែង និងខេត្តស្វាយរៀង (ខេត្តកំពង់ស្ពឺពុំមានរបាយការណ៍) ។

## លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

❖ **ការអនុវត្តយុទ្ធសាស្ត្រទាំង៤**

### ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

**ក.១ ការងារច្បាប់ និងគោលនយោបាយជាតិ**

**ក.១.១-កិច្ចការច្បាប់**

❖ **ច្បាប់ និងលិខិតបទដ្ឋាន ដែលបានដាក់ឲ្យប្រើប្រាស់**

- សន្ធិសញ្ញា ស្តីពី "បត្យាប័ន" រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសរុស្ស៊ី ចុះហត្ថលេខាថ្ងៃទី០១ ខែ០២ ឆ្នាំ២០១៧ (ក្រសួងយុត្តិធម៌)

❖ **លិខិតបទដ្ឋានដែលកំពុងរៀបចំ**

- សេចក្តីព្រាងច្បាប់ ស្តីពី "ការគ្រប់គ្រងការពពោះជំនួស" (ក្រសួងកិច្ចការនារី)
- សេចក្តីព្រាងច្បាប់ ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស" (ក្រសួងយុត្តិធម៌)

- សេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តិ "សម្រាប់អនុវត្តលក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ" (ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ)
- សេចក្ដីព្រាងគោលនយោបាយស្ដីពី "កិច្ចការការពារកុមារតាមសាលារៀន" (ក្រសួងអប់រំ យុវជន និងកីឡា)

**ក.១.២-អនុស្សរណៈនៃការយោគយល់**

❖ **អនុស្សរណៈកំពុងរៀបចំ**

- គណៈកម្មាធិការជាតិ គ.ជ.ប.ជ៖ ត្រៀមពិភាក្សាលើផែនការអនុវត្តកិច្ចព្រមព្រៀង កម្ពុជា-ចិន ស្ដីពី «កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» ។

## ខ.លើកកម្ពស់ការបង្ការទប់ស្កាត់

ការផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរ និងសមត្ថកិច្ច បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយវេទិកាសាធារណៈ តាមភូមិឃុំមានសុវត្ថិភាព និងតាមគោលដៅចំនួន **២.៤៨១**លើក មានអ្នកចូលរួមសរុបចំនួន**៣២០.១៤៩**នាក់ (ធៀបនឹងខែមុនចំនួន**១៤៧.០៧៦**នាក់) កើនឡើងចំនួន**១៧៣.០៧៣**នាក់ ស្មើនឹង**១១៧,៧៦%** ក្នុងនោះស្ត្រីមានចំនួន**១៥០.៩០៩**នាក់ ។ **(ឧបសម្ព័ន្ធទី១)**

**ខ.១-ផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន**

- **ខេត្តកំពត** បានបញ្ចាំងខ្សែភាពយន្តរឿង "**ជើងមេឃនៅឯណា**"ចំនួន**០២**លើក អ្នកចូលរួមចំនួន**៥៦**នាក់ (ស្រី**២៣**នាក់) ។

**ខ.២-គ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍**

**ខ.២.១-ការគ្រប់គ្រងបច្ចុប្បន្នភាពស្ថិតិចំណាកស្រុក**

របាយការណ៍ពីក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការនគរបាលជាតិ) បានចុះធ្វើស្ថិតិពលករចំណាកស្រុកទៅក្រៅប្រទេស សរុប ចំនួន**៣១៩.២៤៧**នាក់ (ស្រី**១៤០.២០១នាក់**) អនីតិជន **៨.៩៦៥**នាក់ (ស្រី**៣.០៥៤**នាក់) ក្នុងនោះស្របច្បាប់ចំនួន**១៧៩.៨៣១នាក់** (ស្រី**៨៣.៦៥៥**នាក់) អនីតិជនចំនួន**៥៨៩**នាក់ (ស្រី**២៤៤**នាក់) មិនស្របច្បាប់ចំនួន**១៣៩.៤១៦**នាក់ (ស្រី**៥៦.៥៤៦**នាក់) អនីតិជនចំនួន**៧.៣៧៦**នាក់(ស្រី**២.៨១០**នាក់) បើប្រៀបធៀបនឹងខែមុនថយចុះ**១.១៩០**នាក់ ស្មើនឹង**០,៣៧១%** ។

**ខ.២.២-ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសឯកជន បញ្ជូនពលករទៅធ្វើការនៅបរទេស**

ក្រុមហ៊ុនឯកជន បានធ្វើការជ្រើសរើសបញ្ជូន និងគ្រប់គ្រង ពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេសចំនួន៤ សរុបចំនួន**១.៦៨៩**នាក់(ស្រីចំនួន**១.០៩៤**នាក់) ក្នុងនោះ៖

- តាមរយៈក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ(EPS)៖ ចំនួន**១៣៣**នាក់ (ស្រី**១៩**នាក់)។
- តាមរយៈភ្នាក់ងារជ្រើសរើសឯកជនមាន៖

| | | |
|---|---|---|
| • ទៅប្រទេសថៃ | ចំនួន**២.៤៧៦**នាក់ | (ស្រី**១.០៣៤**នាក់) |
| • ទៅប្រទេសជប៉ុន | ចំនួន**៧៥**នាក់ | (ស្រី**៣៦**នាក់) |
| • ប្រទេសសិង្ហបូរី | ចំនួន**០៥**នាក់ | (ស្រី**០៥**នាក់) |

**ខ.៣-វិធានការគ្រប់គ្រងជំនាញ**

**ខ.៣.១-ការងារបង្ការទប់ស្កាត់តាមវិធានការជំនាញ**

- ស្នងការដ្ឋាននគរបាល**ខេត្តសៀមរាប និងខេត្តស្វាយរៀង** បានចុះធ្វើស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តអំពើសញ្ញាកម្ម និងផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើ

អាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារ ក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន**១៣៧**គោលដៅ និងមានមនុស្សចំនួន**១.៥៥៥**នាក់ (ស្រី**១.៣៧៨**នាក់)។

- **តាមដាននិងឃ្លាំមើលបាន** ចំនួន**១៣៧គោលដៅ** បើប្រៀបធៀបខែមុនចំនួនគោលដៅមាន **៦២២**គោលដៅ ថយចុះ**៤៨៥**គោលដៅ ស្មើនឹង**៧៧,៩៧%** មនុស្សចំនួន**១.៥៥៥**នាក់ បើប្រៀបធៀប ខែមុនមានចំនួន**២.៩៩៣**នាក់ ថយចុះចំនួន**១.៤៣៨**នាក់ ស្មើនឹង**៤៨.០៤%** (ស្ត្រី**១.៣៧៨**នាក់)។
- **បច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យ**ប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទរាជធានី-ខេត្ត មានចំនួន**៧៥**គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន**០៩**គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៦៦**គោលដៅ ។

### ខ.៣.២-បង្ការទប់ស្កាត់តាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

របាយការណ៍ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ជាសេនាធិការដ្ឋាន បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍បានចំនួន**១២៥**គូ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលរៀបការរួចទៅនៅឯក្រៅប្រទេស ដោយបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់របស់សាមីខ្លួន (រស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា)។

## គ.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១ ការងារអនុវត្តច្បាប់

### គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

ក្រុមការងារអនុវត្តន៍ច្បាប់ បានខិតខំតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន**១៦**ករណី/**១៣**ករណី(បើប្រៀបធៀប ខែមុនថយចុះ**០៣**ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន**១៩**នាក់ (អនីតិជន**០១**នាក់) ស្រីចំនួន**០៦**នាក់ និងជនបរទេស**០២**នាក់ (ជប៉ុន**០១**នាក់ និងអាមេរិក**០១**នាក់) សង្គ្រោះជនរងគ្រោះបានចំនួន**៣៧**នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន**១១**នាក់ អាយុពី១៥-១៧ឆ្នាំចំនួន**០២**នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន២៤នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ចំនួន**១២**នាក់ និង**២៥**នាក់ទៀតប្រគល់ឲ្យគ្រួសារ) ។

➢ **អំពើជួញដូរមនុស្ស**

សរុប**០៥**ករណី/**០២**ករណី ជនសង្ស័យចំនួន**០៨**នាក់(ស្រី**០៤**នាក់) ជនបរទេស**០២**នាក់ (ជប៉ុន និងអាមេរិក) ជនរងគ្រោះចំនួន**១៦**នាក់ អាយុក្រោម១៥ឆ្នាំ**០២**នាក់ អាយុពី១៥-១៧ឆ្នាំ**០១**នាក់ និងអាយុ១៨ឆ្នាំឡើង**១៣**នាក់ (ប្រគល់ឲ្យគ្រួសារ)។

| | |
|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | **០២**ករណី ជនសង្ស័យ **០២**នាក់ |
| -ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | **០១**ករណី ជនសង្ស័យ **០១**នាក់ |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | **០១**ករណី ជនសង្ស័យ **០៣**នាក់ (សញ្ជាតិជប៉ុន**០១**នាក់) |
| -ការទិញពេស្យាចារកុមារ | **០១**ករណី ជនសង្ស័យ **០២**នាក់ (សញ្ជាតិអាមេរិក**០១**នាក់) |

➢ **អំពើធ្វើអាជីវកម្មផ្លូវភេទ**

សរុប**១១**ករណី/**១១**ករណី ជនសង្ស័យចំនួន**១១**នាក់(ស្រី**០២**នាក់) ជនរងគ្រោះចំនួន**២១**នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន**០៩**នាក់ អាយុពី១៥-១៧ឆ្នាំ**០១**នាក់ អាយុ១៨ឆ្នាំឡើងចំនួន**១១**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន**១២**នាក់ និង**០៩**នាក់ ទៀតប្រគល់ឲ្យគ្រួសារ) ។

| | |
|---|---|
| -សញ្ញារកម្ម | ០១ករណី ជនសង្ស័យ ០១នាក់ |
| -សញ្ញារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០១ករណី ជនសង្ស័យ ០១នាក់ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៧ករណី ជនសង្ស័យ ០៧នាក់ (អនីតិជន០១នាក់) |
| -អំពើអាសប្រចាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ករណី ជនសង្ស័យ ០២នាក់ |

**គ.២ កិច្ចការយុត្តិធម៌**

**គ.២.១ លទ្ធផលចំណាត់ការផ្តន្ទាទោស(ពុំមានទិន្នន័យ)**

**គ.២.១-ការរៀបចំបទដ្ឋានគតិយុត្តិ និងច្បាប់**

- សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" កំពុងពិភាក្សាមានៈ
  - សន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលរុស្ស៊ី ។
- សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"បត្យាប័ន" កំពុងពិភាក្សាមានៈ
  - សន្ធិសញ្ញា ស្តីពី "បត្យាប័ន" រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលឥណ្ឌា ។
- សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"បញ្ជូនទណ្ឌិត" កំពុងពិភាក្សាមានៈ
  - សេចក្តីព្រាងកិច្ចព្រមព្រៀង ស្តីពី "បញ្ជូនទណ្ឌិត" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស និង រដ្ឋាភិបាលប៉េរូ និងសាធារណរដ្ឋប្រជាមានិតឡាវ និង រដ្ឋាភិបាលរុស្ស៊ី ។

## ឃ.កិច្ចការពារជនរងគ្រោះ ព្រមទាំងសេវាគាំទ្រ

**ឃ.១ ស្ថិតិពលករដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេស តាមច្រកព្រំដែន**

របាយការណ៍ទទួលពីក្រុមការងារអនុវត្តន៍ច្បាប់ ពលករទេសន្តប្រវេសន៍ការងារបញ្ជូនត្រឡប់មកពីច្រកព្រំដែនកម្ពុជា-ថៃ និងច្រកព្រំដែនកម្ពុជា-វៀតណាម សរុបចំនួន៨.៣៤៩នាក់ (ស្រី២.៩០៩នាក់ កុមារ៧០០នាក់ កុមារី២៧១នាក់) ដែលមកតាម ៖

- ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ **៦.១៦៨**នាក់(ស្រី **២.១៣៣**នាក់ ,កុមារ**៥៨៥**នាក់ ,កុមារី**២៥៦**នាក់)
- ច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង **១.៧៤៤**នាក់ (ស្រី**៦២៣**នាក់ ,កុមារ**៥៤**នាក់)
- ច្រកភ្នំដី ស្រុកសំពៅលូន ខេត្តបាត់ដំបង**៣៩៥**នាក់(ស្រី**១៤៩**នាក់ ,កុមារ**៣៧**នាក់ ,កុមារី**១៣**នាក់)
- ច្រកអានសេះ ខេត្តព្រះវិហារ ០៤នាក់
- អន្តរជាតិបាវិត ខេត្តស្វាយរៀង ៣៨នាក់ (ស្រី០៤នាក់ ,កុមារ២៤នាក់ ,កុមារី០២នាក់)

ចំណែកទេសន្តប្រវេសន៍ចំនួន៥២៦នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ ។ ចំពោះទេសន្តប្រវេសន៍ទាំងអស់នោះ ត្រូវអប់រំណែនាំឲ្យត្រឡប់ទៅលំនៅស្ថានវិញ ។

**ឃ.២-ការសម្ភាសពលករចាប់បញ្ជូនត្រឡប់តាមច្រកព្រំដែន(ផ្លូវគោក និងផ្លូវអាកាស)**

- អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួលពលការរងគ្រោះ ចំនួន១២នាក់ មកពីប្រទេសឥណ្ឌូនេស៊ី១០នាក់ និង០២នាក់ទៀត មកពីប្រទេសឡាវ តាមការសម្ភាសរងគ្រោះដោយទៅដោយខ្លួនឯង (០២នាក់មកប្រទេសឡាវក្រោមការជួយសង្គ្រោះពីស្ថានកុងស៊ុលប្រចាំប្រទេសឡាវ) ។
- ក្រុមការងារការពារជួយជនរងគ្រោះ នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានស្រង់ឈ្មោះជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស តាមរយៈក្រសួងការបរទេស មានចំនួន **៧៧**នាក់ (ស្រី៤៣នាក់, កុមារ១៤នាក់) ក្នុងនោះ៖

- មកពីប្រទេសឥណ្ឌូនេស៊ីចំនួន ១៨នាក់
- មកពីប្រទេសម៉ាឡេស៊ី ចំនួន ១៨នាក់ (ស្រី១៦នាក់)
- មកពីប្រទេសវៀតណាមចំនួន ៣៨នាក់ (ស្រី២៤នាក់ កុមារ១៤នាក់)
- មកពីប្រទេសចិន ចំនួន ០៣នាក់(ស្រី)

**ឃ.៣ ការជួយកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស**

- **អង្គការវេណាសេដើរជាមួយស្ត្រី-កម្ពុជា និងអង្គការក្តីសង្ឃឹម និងយុត្តិធម៌** បានទទួលជនរងគ្រោះ
- ដោយអំពើជួញដូរមនុស្ស និងផ្លូវភេទចំនួន១០នាក់(ស្រី) ជួញដូរផ្លូវភេទ០៦នាក់ និងជួញដូរកម្លាំងពលកម្ម០៤នាក់ ។
- **មន្ទីរ ស.អ.យ ខេត្តក្រចេះ សហការជាមួយអង្គការសង្គ្រោះជោគវាសនាកម្ពុជា** បញ្ជូនកុមាររងគ្រោះ ០១នាក់ ដោយការជួញដូរពលកម្ម ឲ្យទៅរស់នៅក្នុងមណ្ឌលអង្គការ ។

**ឃ.៤ ការគ្រប់គ្រងជនងាយរងគ្រោះនៅក្នុងមណ្ឌល**

- **រាជធានីភ្នំពេញ** បានទទួលជនអនាថាមិនស្ម័គ្រចិត្តសរុបចំនួន១៨៧នាក់ (ស្រី២៩នាក់) ដោយបញ្ជូនជនរងគ្រោះទាំងនេះ ទៅមន្ទីរ ស.អ.យ រាជធានីភ្នំពេញ ដើម្បីអប់រំ និងបណ្តុះបណ្តាលរយៈពេលខ្លី មុននឹងសមាហរណកម្មទៅសហគមន៍វិញ ។
- **ខេត្តកំពង់ចាម** កុមារកំព្រា និងកុមារងាយរងគ្រោះ ការថែទាំនៅក្នុងមណ្ឌល សរុប០៦មណ្ឌល គ្រប់គ្រងដោយមណ្ឌលកុមារកំព្រារដ្ឋ១មណ្ឌល និងអង្គការមិនមែនរដ្ឋាភិបាល០៥មណ្ឌល មានកុមារសរុប២២៩នាក់ (ស្រី៩៨នាក់) និងការថែទាំនៅតាមសហគមន៍ចំនួន០៧អង្គការ សរុប ១.៣៨១នាក់ (ស្រី៤៩នាក់) ។
- **ខេត្តក្រចេះ**
  - មន្ទីរសង្គមកិច្ចខេត្ត សហការជាមួយអង្គការកុមារកម្ពុជា SOSទទួលកុមារកំព្រាឲ្យមករស់នៅសរុបចំនួន៩៨នាក់ (ស្រី៣៩នាក់) និងបានផ្តល់អាហាររូបបត្ថមដល់កុមាររងគ្រោះ និងងាយរងគ្រោះ នៅសហគមន៍ចំនួន៣០០នាក់ (ស្រី១៥៧នាក់)
  - ការិយាល័យសុខុមាលភាពកុមារ ចុះត្រួតពិនិត្យក្នុងមណ្ឌលអង្គការដំណឹងល្អទាំង លើការថែទាំជំនួសចំពោះកុមារ ចំនួន៣២នាក់ (កុមារី១៧នាក់) ។

**ឃ.៥ សេវាជួយជនរងគ្រោះដែលបានផ្តល់**

- **ខេត្តបន្ទាយមានជ័យ** មណ្ឌលសំចតបានបញ្ជូនជនរងគ្រោះ១៧នាក់(ស្រី០៣នាក់) កុមារ១១នាក់ (កុមារី០៧នាក់) ទៅអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ចំនួន១៥នាក់ (ស្រី០៣នាក់) កុមារ១១នាក់ (កុមារី០៥នាក់) និងអង្គការដំណក់ទឹក០២នាក់ (កុមារី០១នាក់) ដើម្បី ទទួលសេវាស្នាក់នៅ អប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសេវាផ្សេងៗក្នុងនោះបានផ្តល់សំលៀកបំពាក់ សំភារៈប្រើប្រាស់ជាប្រចាំ ។

## II. ការលើកកម្ពស់សមត្ថភាព

### ក.ក្នុងប្រទេស

ក.១-បណ្តុះបណ្តាល

- **ខេត្តក្រចេះ៖** ក្រុមការងារមន្ទីរសង្គមកិច្ចខេត្ត បើកវគ្គបណ្តុះបណ្តាលចំនួន០៣វគ្គ ស្តីពីកិច្ចការការពារ ទប់ស្កាត់ការជួញដូរមនុស្ស ការរំលោភបំពាន និងការធ្វើអាជីវកម្មផ្លូវភេទ ដល់ប្រជាពលរដ្ឋសរុបចំនួន១០៣នាក់ (ស្រី៥៦នាក់) ។
- **ខេត្តឧត្តរមានជ័យ៖ មន្ទីរកិច្ចការនារីខេត្ត** បើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស អ្នកចូលរួមចំនួន៤៥នាក់ (ស្រី៣៩នាក់) ។

ក.២-សម្របសម្រួលកិច្ចប្រជុំ

ការងារដឹកនាំសម្របសម្រួលសរុបបានចំនួន៤៣លើក៖ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន១៩លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០៦លើក និងដោយលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន១៨លើក។ (**ឧបសម្ព័ន្ធទី២**)

### ខ.ក្រៅប្រទេស

ខ.១ ចូលរួមប្រជុំ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ចូលរួមប្រជុំពិគ្រោះយោបល់ទ្វេភាគី រវាង រាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃឡង់ដ៍លើកទី១៤ ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស (នៅខេត្តឈៀងម៉ៃ ប្រទេសថៃឡង់ដ៍)។
- **ខេត្តព្រះវិហារ** ចូលរួមប្រជុំជាមួយប្រទេសឡាវ ស្តីពីកិច្ចសហប្រិតបត្តិការ ការពារសន្តិសុខ តាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកដោយប្រថុយប្រថានដើម្បីស្វែងរកការងារធ្វើក្រៅប្រទេស និងពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់ ។

ខ.២-សិក្ខាសាលា

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ចូលរួមសិក្ខាសាលាថ្នាក់តំបន់មេគង្គលើកទី៥៧ ស្តីពីការកំណត់អត្តសញ្ញាណ និងផ្តល់សេវាជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស (នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍)។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បញ្ជូននគរ បាលជាន់ខ្ពស់ ចូលរួមសិក្ខាសាលា ស្តីពីថ្នាក់អនុតំបន់មេគង្គលើកទី៧ ដើម្បីស្រាវជ្រាវរកអត្តសញ្ញាណជនជួញដូរមនុស្ស និងផ្តល់សេវាជួយជនរងគ្រោះ និងចែករំលែកបទពិសោធន៍ឲ្យគ្នារវាងប្រទេសក្នុងអនុតំបន់មេគង្គ (នៅប្រទេសថៃ) ។

## III. សន្និដ្ឋាន និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើងតាមរយៈ ៖

- របាយការណ៍ប្រចាំខែ ពីបណ្តារាជធានី/ខេត្ត និងក្រុមការងារ
- តាមដានការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របដល់ជនរងគ្រោះក្រោយការបណ្តុះបណ្តាលរួចមាន៖ (ខេត្តកណ្តាល,បន្ទាយមានជ័យ,សៀមរាប,រាជធានីភ្នំពេញ និងខេត្តកំពង់ចាម)
- ការចុះតាមដានការអនុវត្តការងារមន្ត្រីនគរបាលយុត្តិធម៌ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងពេលប្រតិបត្តិការ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជាគជ័យគួរកត់សម្គាល់៖

១.បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្ររបស់ក្រុមការងារទាំង៦និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកិច្ចការ ការងារបង្ការទប់ស្កាត់និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ។

២.របៀបរបបការងារ និងទំនាក់ទំនងសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ត្រូវបានពង្រឹង និង

ពង្រីកយ៉ាងទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួមតែមួយ ។

៣. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់ ។

៤. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព ។

**ខ. ចំណុចខ្វះខាត និងបញ្ហាប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ការផ្តល់របាយការណ៍ ពីក្រុមការងារ និងរាជធានី/ខេត្ត មួយចំនួនមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីធ្វើការបូកសរុបមានការយឺតយ៉ាវ ។
- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់នៅមានកម្រិត ដែលទាមទារឲ្យពង្រឹងបន្ថែម ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍នៃបទល្មើស ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ក្នុងនោះមានជនរងគ្រោះ នៅមិនទាន់ឆ្លើយតបទាន់សភាពការណ៍ ។
- ការទទួលព័ត៌មាន និងការអប់រំ ផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយាល ដែលជាចំណុចចន្លោះប្រហោងមួយសម្រាប់ពួកឈ្មួញទុច្ចរិតងាយធ្វើការអូសទាញ បោកបញ្ឆោតទាំងបុរស ស្ត្រី និងកុមារ ឲ្យជឿជាក់ និងធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការខ្វះខាត ហើយចំណេះដឹងនិងការអប់រំ របស់ពួកគាត់នៅមានកម្រិតដូច្នេះទើបធ្វើឲ្យពួកគាត់ ធ្វើការសម្រេចចិត្តរួសរាន់ទៅតាមការអូសទាញរបស់ឈ្មួញទុច្ចរិត។
- រចនាសម្ព័ន្ធ នៃគណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន មិនទាន់បានរៀបចំត្រឹមត្រូវច្បាស់លាស់ ក្នុងការធ្វើការតាមដានការងារជាប្រចាំ និងពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយលើការងារថ្នាក់ក្រោមជាតិ ។

## IV. ទិសដៅខែមិនា ឆ្នាំ២០១៧

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួម បែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ជួញដូរ និងជកហូតសរីរាង្គ ជួញដូរ និងរត់ពន្ធទារក និងកុមារ ឆ្លងដែន ការជួញដូរពលកម្មក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។ ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។

៣. រៀបចំសកម្មភាពសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ពាក់កណ្តាល អាណត្តិទី២ ៖ ២០១៧-២០១៨) ។

# ឧបសម្ព័ន្ធទី១

## ការងារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ផ្សព្វផ្សាយស្តីពីច្បាប់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ភូមិ/ឃុំ មានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស )(ស្វាយរៀង ១៥លើក =៨៦នាក់ ពោធិ៍សាត់ ០១លើក =១,៦០២នាក់ និងកំពត ០៨លើក ៥៣នាក់ ) ។ | ស្នងការដ្ឋាននគរបាលខេត្ត | 22 លើក | 1,741 នាក់ | 906 នាក់ |
| 2 | កណ្តាល | វេទិកាសាធារណៈនគរបាលជួបជាមួយ សហគមន៍ ដោយបញ្ជ្រាបការផ្សព្វផ្សាយ ស្តីពីការអនុវត្ត គោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាពទាំង៩ចំណុច ដល់ប្រជាពលរដ្ឋ ។ | ក្រុមការងារថ្នាក់ក្រុង/ស្រុក ឃុំ/សង្កាត់ | 195 លើក | 10,544 នាក់ | 5,424 នាក់ |
| | | ផ្សព្វផ្សាយច្បាប់ស្តី អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ។ | មន្ទីរ ក្រុង ស្រុក | 50 លើក | 9,445 នាក់ | 5,444 នាក់ |
| 3 | ព្រះវិហារ | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 7 លើក | 982 នាក់ | 335 នាក់ |
| | | ផ្សព្វផ្សាយអំពីការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថភាព ដល់ប្រជាពលរដ្ឋ ។ | ក្រុមការងារថ្នាក់ស្រុក | 8 លើក | 2,083 នាក់ | 789 នាក់ |
| 4 | ក្រចេះ | ផ្សព្វផ្សាយ ច្បាប់ស្តីពីការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ កិច្ចការពារជនរងគ្រោះ ការធ្វើចំណាក ស្រុកដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរកិច្ចការនារី | 3 លើក | 157 នាក់ | 122 នាក់ |
| 5 | កំពង់ឆ្នាំង | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ច្បាប់ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 407 លើក | 79,903 នាក់ | 26,449 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កិច្ចការពារជនរងគ្រោះ ដោយបញ្ជ្រាបតាមគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត ក្រុមការងារថ្នាក់ភូមិ ស្រុក | 292 លើក | 48,123 នាក់ | 26,052 នាក់ |
| 6 | កំពត | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 4 លើក | 380 នាក់ | 164 នាក់ |
| 7 | កោះកុង | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការជួញដូរមនុស្ស នៅតាមភូមិឃុំ /សង្កាត់ទូទាំងខេត្ត ដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 30 លើក | 1,863 នាក់ | 931 នាក់ |
| | | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការអនុវត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាពទាំង១២ក្រុង ស្រុក ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 245 លើក | 17,812 នាក់ | 10,062 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 8 | សៀមរាប | ផ្សព្វផ្សាយ លើការងារព្រឹងសមត្ថភាព តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់សមត្ថកិច្ចមូលដ្ឋានឲ្យមានសមត្ថភាព និងប្រសិទ្ធភាព ក្នុងការទប់ស្កាត់ការជួញដូរកម្លាំងពលកម្មកុមារ និងការធ្វើ ចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត និងក្រុមការងារថ្នាក់ស្រុក | 39 លើក | 5,359 នាក់ | 2,981 នាក់ |
| 9 | តាកែវ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅតាមភូមិ ឃុំ សង្កាត់ ដល់ប្រជាពលរដ្ឋ និងសំណូមពររបស់ពួកគាត់ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 11 លើក | 656 នាក់ | 245 នាក់ |
| | | ផ្សព្វផ្សាយ ច្បាប់ស្តីពីទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបញ្ជ្រាប ក្នុងការអនុវត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរកិច្ចការនារី | 17 លើក | 1,068 នាក់ | 407 នាក់ |
| 10 | ពោធិ៍សាត់ | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 81 លើក | 10,115 នាក់ | 4,536 នាក់ |
| | | ផ្សព្វផ្សាយ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ។ | ក្រុមការងារថ្នាក់ស្រុក | 257 លើក | 38,625 នាក់ | 19,719 នាក់ |
| 11 | រតនៈគិរី | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 11 លើក | 578 នាក់ | 200 នាក់ |
| 12 | បាត់ដំបង | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាល | 50 លើក | 10,973 នាក់ | 6,256 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ប្រជាពលរដ្ឋ ។ | | 406 លើក | 54,992 នាក់ | 27,869 នាក់ |
| 13 | កែប | ចូលរួមបញ្ជ្រាបការទប់ស្កាត់ការធ្វើចំណាកស្រុកដោយខុសច្បាប់ និងផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវេទិកាផ្សព្វផ្សាយ ស្តីពីគោលនយោបាយ ភូមិ/ឃុំ មានសុវត្ថិភាព។ | លេខាធិការដ្ឋានខេត្ត | 66 លើក | 7,172 នាក់ | 3,462 នាក់ |
| 15 | ឧត្តរមានជ័យ | វេទិកាផ្សព្វផ្សាយ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ កិច្ចការពារជនរងគ្រោះ យន្តការទេសន្តរប្រវេសន៍ និងការកេងប្រវ័ញ្ចនានា ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋានខេត្ត និងមន្ទីរកិច្ចការនារីខេត្ត | 3 លើក | 1,652 នាក់ | 827 នាក់ |
| 16 | ស្វាយរៀង | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 250 លើក | 12,794 នាក់ | 6,556 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្មសង្ស័យមានពាក់ព័ន្ធបទល្មើសផ្លូវភេទ ដូចជា ខារ៉ាអូខេ សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួលម៉ាស្សា កោសជប់ ផ្ទះលក់ការហ្វេរីដេអូ និងជួល លក់វីស៊ីឌី ។ | | 12 លើក | 67 នាក់ | 49 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 16 | ព្រះសីហនុ | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 7 លើក | 982 នាក់ | 335 នាក់ |
| | | ផ្សព្វផ្សាយអំពីការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ។ | ក្រុមការងារថ្នាក់ស្រុក | 8 លើក | 2,083 នាក់ | 789 នាក់ |

សកម្មភាពសរុបៈចំនួនៈ **2,481 លើក**

មនុស្សសរុបចំនួនៈ **320,149 នាក់**

ស្រីសរុបចំនួន : **150,909 នាក់**

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៤៣លើក)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | - ប្រជុំអន្តរក្រសួង ស្តីពីដំណោះស្រាយបញ្ហាពពោះជំនួស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគជ.ប.ជ.** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ជំនួបពិភាក្សា ជាមួយលោកជំទាវ **Donica Pottie** ឯកអគ្គរដ្ឋទូតកាណាដា ដែលទើបតែងតាំងថ្មី នៅទីស្តីការក្រសួងមហាផ្ទៃ និងបន្តកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- រៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ ជ.ប.ជ.**នៅទីស្តីការក្រសួងមហាផ្ទៃ។ |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | - ដឹកនាំប្រជុំក្នុងកែសម្រួលរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០១៦ នៅសាលប្រជុំ គ.ជ.ប.ជ (**០៤លើក**)។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីដំណោះស្រាយបញ្ហាពពោះជំនួស នៅសាលប្រជុំ គ.ជ.ប.ជ ។<br>- អញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលការប្រចាំឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ ។<br>- អញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំលើកទី៨ របស់ក្រុមការងារ បច្ចេកទេសកម្ពុជា នៃកម្មវិធីអូស្ត្រាលី-អាស៊ី ដើម្បីប្រឆាំងការជួញដូរមនុស្ស ហៅកាត់ថា (AAPTIP) នៅសាលប្រជុំក្រសួងយុត្តិធម៌ ។<br>- អញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាកុមារ នៅទីស្តីការក្រសួងសង្គមកិច្ច។<br>- អញ្ជើញចូលរួមសិក្ខាសាលាពិភាក្សាអំពីផែនទីបង្ហាញផ្លូវ និងមធ្យោបាយឆ្ពោះទៅរកការបង្កើតប្រព័ន្ធការពារកុមារថ្នាក់ជាតិ ជាមួយអង្គការកុមារឥតព្រំដែន នៅភោជនីយ៍ដ្ឋានអ័រគីដេប៉ាស្វ័រ។<br>- អញ្ជើញចូលរួមប្រជុំបូកសរុប ដំណើរការចំណុចខ្ពស់វាយលុកបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែនរវាងកម្ពុជា-វៀតណាម ក្រោមអធិបតីភាព **ឯកឧត្តមនាយឧត្តមសេនីយ៍ នេត សាវឿន** អគ្គស្នងការនគរបាលជាតិ នៅសណ្ឋាគារភ្នំពេញ ។<br>- អញ្ជើញចូលរួមប្រជុំឆ្លងសេចក្តីព្រាងរបាយការណ៍សន្និបាតបូកសរុប ការងារសម្រាប់ឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងឯកសារពាក់ព័ន្ធបម្រើការងារសន្និបាត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ ។ |

| | |
|---|---|
| | - បានដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលនៃអគ្គលេខាធិការដ្ឋាន។ បានប្រជុំដួរត្រួតពិនិត្យកម្លាំងរាល់ថ្ងៃច័ន្ទពេលព្រឹក ។<br>- ជួបប្រជុំពិភាក្សាជាមួយអង្គការ VCAO លើការងារជួយសេវាដល់ ជនរងគ្រោះដែលធ្វើចំណាកស្រុកច្រើន ដើម្បីធ្វើយ៉ាងណាឲ្យពួកគាត់អាចរស់បានដោយពុំចាំបាច់ធ្វើចំណាកស្រុកសម្រាប់ឆ្នាំ២០១៨ ។<br>- អញ្ជើញចូលរួមប្រជុំបច្ចេកទេសលើលទ្ធផលការសិក្សាស្រាវជ្រាវ ស្តីពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកមកលើកុមារកម្ពុជា នៅសណ្ឋាគារសាន់វេ រៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ ។<br>- ជួបពិភាក្សាជាមួយលោកស្រី Vimala នាយិការអង្គការកុមារឥតព្រំដែន ស្តីពីការបង្កើតផែនទីបង្ហាញផ្លូវឆ្ពោះទៅការបង្កើតប្រព័ន្ធការពារកុមារកម្ពុជា ។<br>- បានទំនាក់ទំនងការិយាល័យទំនាក់ទំនងព្រំដែន របស់អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ ដើម្បីស្នើសុំចំនួនសពពលករខ្មែរដែលបានស្លាប់ និងបញ្ជូនមកតាមព្រំដែន ក្នុងឆ្នាំ២០១៦ ។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - ប្រជុំ ស្តីពីការពង្រឹងកិច្ចសហការជាមួយអង្គការដៃគូមិនមែនរដ្ឋាភិបាល និងការងារពាក់ព័ន្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ។<br>- ចូលរួមប្រជុំក្នុងការឆ្លើយតបការស្នើសុំព័ត៌មាន នីតិវិធី និងបទបញ្ញាតិច្បាប់ពាក់ព័ន្ធនឹងការសុំកូនអន្តរប្រទេស ។<br>- ចូលរួមប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យទៅលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ។<br>- ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារដោះស្រាយបញ្ហាជនអនាថា ប្រចាំឆ្នាំឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ។<br>- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសអនុវត្តកម្មវិធីអាបទីប AAPTIP លើកទី០៨ នៅក្រសួងយុត្តិធម៌។<br>- ចូលរួមកិច្ចប្រជុំពិនិត្យ-ពិភាក្សា និងសម្រេចចុងក្រោយ លើផែនការសកម្មភាពខមីត និងផែនការក្រុមការងារសហប្រតិបត្តិការអន្តរជាតិសម្រាប់ឆ្នាំ២០១៧ ។ |
| ខេត្តក្រចេះ | - ប្រជុំក្រុមការងារខេត្ត ស្តីពីការអនុវត្តក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើទិសដៅអនុវត្តបន្ត សមាសភាពចូលរួមចំនួន០៧នាក់ (ស្រី០២នាក់)។ |
| ខេត្តឧត្តរមានជ័យ | - ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយពីតួនាទី និងភារកិច្ចដល់មន្ត្រីពាក់ព័ន្ធក្រុង ស្រុក ឃុំ សង្កាត់ ក្នុងការអនុវត្តន៍ផែនការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងយន្តការចំណាកស្រុកដោយសុវត្ថិភាព ដឹកនាំដោយលោកជំទាវ អភិបាលរងខេត្ត ទទួលបន្ទុកការងារជួញដូរមនុស្ស អ្នកចូលរួមចំនួន៣១៥នាក់ (ស្រី៧៧នាក់)។<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់ការជួញដូរមនុស្ស សរុបអ្នកចូលរួមចំនួន៨៤នាក់ (ស្រី៣៨នាក់)។ |
| ខេត្តព្រះវិហារ | - ក្រុមការងារបង្ការ ទប់ស្កាត់ នៃលេខាធិការដ្ឋានខេត្ត បានប្រជុំចំនួន០១លើក អ្នកចូលរួមចំនួន០៥នាក់ (ស្រី០១នាក់)។ |
| ខេត្តសៀមរាប | - ប្រជុំប្រចាំខែ ដែលមានសមាជិក និងអង្គការដៃគូជាតិ អន្តរជាតិ ចូលរួមសរុបចំនួន៣៨នាក់ (ស្រី១៩នាក់)។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត ចូលរួមធ្វើជាវាគ្មិន ក្នុងវគ្គសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការ |

| | |
|---|---|
| | ប្រឆាំងអំពើជួញដូរមនុស្ស និងទប់ស្កាត់អំពើហិង្សា រៀបចំដោយអង្គការព្រាបកម្ពុជា អ្នកចូលរួមចំនួន៥៥នាក់ ។<br>- មន្ទីរព័ត៌មានខេត្ត សហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរ ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គភាពពាក់ព័ន្ធ ចូលរួមជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ទនាមតិ និងផ្សព្វផ្សាយច្បាប់ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកមិនស្របច្បាប់ ជាពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលនៅក្នុងខេត្ត ០៩ប្រធានបទ ។ |
| ខេត្តកំពង់ចាម | - ចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ ការអន្តរាគមន៍ និងសង្គ្រោះស្ត្រីរងគ្រោះធ្វើការនៅក្រៅប្រទេស ។<br>- ថ្ងៃទី៣១ មករា ឆ្នាំ២០១៧ សន្និបាតបូលសរុបការងាររដ្ឋបាលដែនដី ការអនុត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១១៧ ។<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ។ |
| ខេត្តបន្ទាយមានជ័យ | - ចូលរួមប្រជុំ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី២ ។<br>- បញ្ជូនមន្ត្រី២រូប ចូលរួមប្រជុំត្រួតពិនិត្យការអនុវត្ត គោលការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក យក់ សុខា អគ្គស្នងការរង ទទួលផែននគរបាលយុត្តិធម៌ អ្នកចូលរួមចំនួន៣៥នាក់ ស្រី១៧នាក់ (នៅស្នងការដ្ឋាន ខេត្តសៀមរាប)។ |
| ខេត្តប៉ៃលិន | - ចូលរួមប្រជុំ គ ក ស ក ផ្សព្វផ្សាយពីបញ្ហាការទប់ស្កាត់ ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ។<br>- ចូលរួមប្រជុំ ជាមួយ គ ក ស ក នៅសង្កាត់ទួលល្វា អំពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រជាពលរដ្ឋក្នុងសង្កាត់។<br>- លោកជំទាវអភិបាលរង ទទួលបន្ទុកគ.ឌ.ប.ជ អញ្ជើញចូលរួមសន្និបាតបូលសរុបការងារប្រចាំឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ។ |
| ខេត្តតាកែវ | - លោកជំទាវអភិបាលរង ទទួលបន្ទុកគ.ឌ.ប.ជ អញ្ជើញចូលរួមសន្និបាតបូលសរុបការងារប្រចាំឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ។ |
| ខេត្តកណ្តាល | - ក្រុមការងារលេខាធិការដ្ឋានថ្នាក់ស្រុក បើកកិច្ចប្រជុំប្រចាំខែ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួម**៤៦**នាក់ ស្រី**២៥**នាក់ (**០២**លើក) ។ |